**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០០៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១២

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤ :**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥ :**

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦ :**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧ :**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨ :**

កម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១០០៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | ពិនិត្យកាយសម្បទាមុនចូលធ្វើការកម្មករនិយោជិតខ្មែរ | 20,000 | 7ថ្ងៃ | |
| 2 | ពិនិត្យកាយសម្បទាមុនចូលធ្វើការសម្រាប់ជនបរទេស | 100,000 | 7ថ្ងៃ | |
| 3 | ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរ មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | | | |
| | - នៅរាជធានីភ្នំពេញ | 24,000 | 1ថ្ងៃ | |
| | - នៅតាមបណ្តាខេត្ត | 28,000 | 1ថ្ងៃ | |
| 4 | ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតបរទេស មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | | | |
| | - នៅរាជធានីភ្នំពេញ | 110,000 | 1ថ្ងៃ | |
| | - នៅតាមបណ្តាខេត្ត | 120,000 | 1ថ្ងៃ | |
| 5 | ពិនិត្យសុខភាពពលករខ្មែរទៅបម្រើការងារនៅបរទេស ពិនិត្យសុខភាពសិក្ខាកាមខ្មែរទៅបរទេស (តាមការស្នើសុំ) | | | |
| 5.1 | ការធានាសេវាបញ្ជូនពលករ(សេវាបកប្រែឯកសារជាភាសាអង់គ្លេស) | 40,000 | | |
| 5.2 | សេវាគ្រូពេទ្យពិនិត្យ(ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត បេះដូង កាយសម្បទា) | 10,000 | | |
| 5.3 | សេវាថតវិទ្យុសាស្ត្រ | 18,000 | | |
| 5.4 | សេវាមន្ទីរពិសោធន៍ | | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 5.4.1 | ផ្នែកទី1 : ពិនិត្យឈាម | | | |
| | Hematocrite | 4,000 | 2ថ្ងៃ | |
| | Hematology test ( Hg+Vs ) | 10,000 | 2ថ្ងៃ | |
| | Blood Group | 4,000 | 2ថ្ងៃ | |
| | Sugar | 5,000 | 2ថ្ងៃ | |
| | Total Cholesterol | 8,000 | 2ថ្ងៃ | |
| | HDL-Cholesterol | 7,000 | 2ថ្ងៃ | |
| | LDL-Cholesterol | 9,000 | 2ថ្ងៃ | |
| | Triglyceride | 6,000 | 2ថ្ងៃ | |
| | Calcium | 5,000 | 2ថ្ងៃ | |
| | Uric Acid | 5,000 | 2ថ្ងៃ | |
| | Albumin | 5,000 | 2ថ្ងៃ | |
| | Creatinine | 6,000 | 2ថ្ងៃ | |
| | Blood Urea | 6,000 | 2ថ្ងៃ | |
| | Serum Iron | 7,000 | 2ថ្ងៃ | |
| | HIV Antibody ( Elisa ) | 25,000 | 2ថ្ងៃ | |
| | HBs Ag ( Elisa ) | 18,000 | 2ថ្ងៃ | |
| | HBs Ab | 20,000 | 2ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | HCV Ab | 34,000 | 2ថ្ងៃ | |
| | HAV IgM | 40,000 | 2ថ្ងៃ | |
| | HAV IgG | 40,000 | 2ថ្ងៃ | |
| | GOT | 6,000 | 2ថ្ងៃ | |
| | GPT | 6,000 | 2ថ្ងៃ | |
| | Gamma-GT | 6,000 | 2ថ្ងៃ | |
| | VDRL ( RPR ) | 10,000 | 2ថ្ងៃ | |
| | TPHA | 10,000 | 2ថ្ងៃ | |
| | Malaria Parasite | 6,000 | 2ថ្ងៃ | |
| | Widal | 6,000 | 2ថ្ងៃ | |
| | Blood Conservation ( 4Months ) | 26,000 | 2ថ្ងៃ | |
| 5.4.2 | ផ្នែកទី2 : ពិនិត្យទឹកនោម | | | |
| | Albumin, Sugar ( +Pregnancy Test ) | 8,000 | 2ថ្ងៃ | |
| | Morphine | 22,000 | 2ថ្ងៃ | |
| | Methamphetamine | 22,000 | 2ថ្ងៃ | |
| 5.4.3 | ផ្នែកទី3 : ផ្សេងៗ | | | |
| | Hearing Acuity | 30,000 | 2ថ្ងៃ | |
| | ECG | 20,000 | 2ថ្ងៃ | |
| | Heart Ultra-sound | 60,000 | 2ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 6 | បញ្ជាក់លើវិញ្ញាបនប័ត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសតាមការស្នើសុំ (ក្នុង 1នាក់) | 20,000 | 1ថ្ងៃ | |
| 7 | វគ្គបណ្តុះបណ្តាលគ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ មុនចូលបម្រើការងារតាមសហគ្រាស (ក្នុង 1នាក់) | 200,000 | | |
| 8 | បណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារសម្រាប់និយោជក និងតំណាងកម្មករ និយោជិត (ក្នុង 1នាក់) | | | |
| | - នៅរាជធានីភ្នំពេញ | 50,000 | | |
| | - នៅតាមបណ្តាខេត្ត | 80,000 | | |
| 9 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា | 10,000 | 8ថ្ងៃ | អចិន្ត្រៃយ៍ |
| 10 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស | 400,000 | 8ថ្ងៃ | 1ឆ្នាំ |
| 11 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (តំបន់អភិវឌ្ឍន៍ត្រីកោណ) | 320,000 | 8ថ្ងៃ | 1ឆ្នាំ |
| 12 | ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍) | 240,000 | 8ថ្ងៃ | |
| 13 | ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ | 80,000 | 8ថ្ងៃ | 1ឆ្នាំ |
| 14 | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក | | | |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 08នាក់ - 100នាក់ | 80,000 | 7ថ្ងៃ | ២ឆ្នាំ |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 101នាក់ - 500នាក់ | 150,000 | 7ថ្ងៃ | ២ឆ្នាំ |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 501នាក់ - 800នាក់ | 250,000 | 7ថ្ងៃ | ២ឆ្នាំ |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 801នាក់ឡើងទៅ | 400,000 | 7ថ្ងៃ | ២ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 15 | ការចុះបញ្ជិកាសំណុំបែបបទ ស្តីពីគ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 01នាក់ - 07នាក់ ( មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 20,000 | 15ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 20,000 | 7ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 40,000 | 7ថ្ងៃ | |
| 16 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 08នាក់ - 100នាក់ ( មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 30,000 | 15ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 40,000 | 7ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 60,000 | 7ថ្ងៃ | |
| | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង | 70,000 | 60ថ្ងៃ | |
| 17 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 101នាក់ - 500នាក់ ( នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 100,000 | 15ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 80,000 | 7ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 120,000 | 7ថ្ងៃ | |
| | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង | 300,000 | 60ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 18 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 501នាក់ឡើងទៅ ( នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 200,000 | 15ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 80,000 | 7ថ្ងៃ | |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 120,000 | 7ថ្ងៃ | |
| | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង | 600,000 | 60ថ្ងៃ | |
| 19 | លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង | 100,000 | 7ថ្ងៃ | 2ខែ |
| 20 | សំណុំបែបបទហ្វឹកហ្វឺនកូនជាងមួយឈុត | 3,000 | | |
| 21 | ការចេញប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ | 3,000 | | |
| 22 | ការចេញវិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង | 12,000 | | |
| 23 | ការចុះហត្ថលេខាលើសញ្ញាបត្រសិស្ស-និស្សិតបង់ថ្លៃ | 8,000 | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០១០ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម
## ស្តីពី
## ការផ្តល់ទ្រូវ៉ាន់លើកទឹកចិត្តជូន
## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១០០៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ ៣** :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០០៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

**ប្រការ ៥** :

រដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិកានៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងការងារ និះបណ្តុះបណ្តាលវិជ្ជាជីវៈដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃកាធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាងស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្តត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយ-ការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយ-ការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៧** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៨ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

### ភ្ជាប់នឹងប្រកាសរួមលេខ ១០១០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

### ស្តីពីការផ្តល់ទ្វាន់លើកទឹកចិត្ត ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(ក. កបវ) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. កបវ | ក. សហវ |
| 1 | ពិនិត្យកាយសម្បទាមុនចូលធ្វើការកម្មករនិយោជិតខ្មែរ | 10% | 89% | 1% |
| 2 | ពិនិត្យកាយសម្បទាមុនចូលធ្វើការសម្រាប់ជនបរទេស | 10% | 89% | 1% |
| 3 | ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរ មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | | | |
| | - នៅរាជធានីភ្នំពេញ | 10% | 89% | 1% |
| | - នៅតាមបណ្តាខេត្ត | 10% | 89% | 1% |
| 4 | ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតបរទេស មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | | | |
| | - នៅរាជធានីភ្នំពេញ | 10% | 89% | 1% |
| | - នៅតាមបណ្តាខេត្ត | 10% | 89% | 1% |
| 5 | ពិនិត្យសុខភាពពលករខ្មែរទៅបម្រើការងារនៅបរទេស ពិនិត្យសុខភាពសិក្ខាកាមខ្មែរទៅបរទេស (តាមការស្នើសុំ) | | | |
| 5.1 | ការធានាសេវាបញ្ជូនពលករ(សេវាបកប្រែឯកសារជាភាសាអង់គ្លេស) | 10% | 89% | 1% |
| 5.2 | សេវាគ្រូពេទ្យពិនិត្យ(ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត បេះដូង កាយសម្បទា) | 10% | 89% | 1% |
| 5.3 | សេវាថតវិទ្យុសាស្ត្រ | 10% | 89% | 1% |
| 5.4 | សេវាមន្ទីរពិសោធន៍ | | | |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. កបវ | ក. សហវ |
| 5.4.1 | ផ្នែកទី1 : ពិនិត្យឈាម | | | |
| | Hematocrite | 10% | 89% | 1% |
| | Hematology test ( Hg+Vs ) | 10% | 89% | 1% |
| | Blood Group | 10% | 89% | 1% |
| | Sugar | 10% | 89% | 1% |
| | Total Cholesterol | 10% | 89% | 1% |
| | HDL-Cholesterol | 10% | 89% | 1% |
| | LDL-Cholesterol | 10% | 89% | 1% |
| | Triglyceride | 10% | 89% | 1% |
| | Calcium | 10% | 89% | 1% |
| | Uric Acid | 10% | 89% | 1% |
| | Albumin | 10% | 89% | 1% |
| | Creatinine | 10% | 89% | 1% |
| | Blood Urea | 10% | 89% | 1% |
| | Serum Iron | 10% | 89% | 1% |
| | HIV Antibody ( Elisa ) | 10% | 89% | 1% |
| | HBs Ag ( Elisa ) | 10% | 89% | [illegible] |
| | HBs Ab | 10% | 89% | [illegible] |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. កបវ | ក. សហវ |
| | HCV Ab | 10% | 89% | 1% |
| | HAV IgM | 10% | 89% | 1% |
| | HAV IgG | 10% | 89% | 1% |
| | GOT | 10% | 89% | 1% |
| | GPT | 10% | 89% | 1% |
| | Gamma-GT | 10% | 89% | 1% |
| | VDRL ( RPR ) | 10% | 89% | 1% |
| | TPHA | 10% | 89% | 1% |
| | Malaria Parasite | 10% | 89% | 1% |
| | Widal | 10% | 89% | 1% |
| | Blood Conservation ( 4Months ) | 10% | 89% | 1% |
| 5.4.2 | ផ្នែកទី២ : ពិនិត្យទឹកនោម | | | |
| | Albumin, Sugar( +Pregnancy test ) | 10% | 89% | 1% |
| | Morphine | 10% | 89% | 1% |
| | Methamphetamine | 10% | 89% | 1% |
| 5.4.3 | ផ្នែកទី៤ : ផ្សេងៗ | | | |
| | Hearing Acuity | 10% | 89% | 1% |
| | ECG | 10% | 89% | 1% |
| | Heart Ultra-sound | 10% | 89% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. កបវ | ក. សហវ |
| 6 | បញ្ជាក់លើវិញ្ញាបនប័ត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសតាមការស្នើសុំ(ក្នុង១នាក់) | 10% | 89% | 1% |
| 7 | វគ្គបណ្តុះបណ្តាលគ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ មុនចូលបម្រើការងារតាមសហគ្រាស (គិតម្នាក់ៗ) | 10% | 89% | 1% |
| 8 | បណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារសម្រាប់និយោជក និងតំណាងកម្មករ និយោជិត (គិតម្នាក់ៗ) | | | |
| | - នៅរាជធានីភ្នំពេញ | 10% | 89% | 1% |
| | - នៅតាមបណ្តាខេត្ត | 10% | 89% | 1% |
| 9 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា | 50% | 49% | 1% |
| 10 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស | 70% | 29% | 1% |
| 11 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (តំបន់អភិវឌ្ឍន៍ត្រីកោណ) | 70% | 29% | 1% |
| 12 | ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍) | 70% | 29% | 1% |
| 13 | ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ | 50% | 49% | 1% |
| 14 | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក | | | |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ០៨នាក់-១០០នាក់ | 50% | 49% | 1% |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ១០១នាក់-១០០នាក់ | 50% | 49% | 1% |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ៥០១នាក់-៨០០នាក់ | 50% | 49% | 1% |
| | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ៨០១នាក់ឡើង | 50% | 49% | [illegible] |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. កបវ | ក. សហវ |
| 15 | ការចុះបញ្ជិកាសំណុំបែបបទ ស្តីពីគ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 01នាក់ - 07នាក់ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 50% | 49% | 1% |
| 16 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 08នាក់ - 100នាក់ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រឹសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 50% | 49% | 1% |
| | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង | 50% | 49% | 1% |
| 17 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 101នាក់ - 500នាក់ (នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រឹសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 50% | 49% | 1% |
| | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក. កបវ | ក. សហវ |
| 18 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 501នាក់ឡើងទៅ ( នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ ) | | | |
| | - ចុះបញ្ជិកា ប្រកាសបើកសហគ្រាស | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 50% | 49% | 1% |
| | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 50% | 49% | 1% |
| | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង | 50% | 49% | 1% |
| 19 | លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង | 50% | 49% | 1% |
| 20 | សំណុំបែបបទហ្វឹកហ្វឺនកូនជាងមួយឈុត | 10% | 89% | 1% |
| 21 | ការចេញប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ | 10% | 89% | 1% |
| 22 | ការចេញវិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង | 10% | 89% | 1% |
| 23 | ការចុះហត្ថលេខាលើសញ្ញាបត្រសិស្ស-និស្សិតបង់ថ្លៃ | 10% | 89% | 1% |

**បញ្ជាក់:** ចំពោះចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត [illegible] ជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវអនុវត្តដូចអត្រា[illegible] តារាងឧបសម្ព័ន្ធនេះ។